ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៣៨ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែម សម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ៧៧ សសរ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ ១៩៨៣ ស្តីពីការកម្រិតប្រាក់កម្រៃម៉ោងបន្ថែម សម្រាប់កម្មាភិបាល បុគ្គលិក គ្រូបង្រៀន និងសាស្ត្រាចារ្យ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែមិនា ឆ្នាំ ១៩៩២ ស្តីពីការកែលម្អបៀវត្ស កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ

– តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
– តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.–**

– ដែលហៅថាម៉ោងកំណត់ គឺជារយៈពេលគិតជាម៉ោងក្នុងមួយសប្ដាហ៍ ដែលគ្រូបង្រៀន និងសាស្ត្រាចារ្យ មានកាតព្វកិច្ចបង្រៀន និងបំពេញការងារគរុកោសល្យនៅក្នុងគ្រឹះស្ថានសិក្សា ។
– ដែលហៅថាម៉ោងបន្ថែម គឺជារយៈពេលគិតជាម៉ោងដែលគ្រូបង្រៀន និងសាស្ត្រាចារ្យបានបង្រៀន និងបំពេញការងារគរុកោសល្យ លើសពីម៉ោងកំណត់ ។

**មាត្រា ២.–**

អំពីចំនួនម៉ោងប្រចាំសប្ដាហ៍ៈ

ក) ចំពោះគ្រូបង្រៀន និងសាស្ត្រាចារ្យ ដែលមានមុខងារ និងឋានៈត្រូវនឹងកម្រិតសិក្សាដែលបង្រៀនមាន កំណត់ដូចខាងក្រោមៈ

| គ្រឹះស្ថានសិក្សា ឬ ថ្នាក់បណ្ដុះបណ្ដាល | ចំនួនម៉ោងបង្រៀនទ្រឹស្ដីប្រចាំសប្ដាហ៍ | ចំនួនម៉ោងអនុវត្ត–រៀបចំការងារបង្រៀន–កំណែប្រចាំសប្ដាហ៍ |
|---|---|---|
| **ផ្នែកចំណេះទូទៅ** | | |
| – អនុវិទ្យាល័យ | ១៨ ម៉ោង | ២០ ម៉ោង |
| – វិទ្យាល័យ | ១៦ ម៉ោង | ១៨ ម៉ោង |
| **ផ្នែកមុខជំនាញ** | | |
| – បណ្ដុះបណ្ដាលវិជ្ជាជីវៈ | ១៦ ម៉ោង | ១៨ ម៉ោង |
| – មធ្យមសិក្សាបច្ចេកទេស | ១៤ ម៉ោង | ១៨ ម៉ោង |
| – ឧត្ដមសិក្សា | ១២ ម៉ោង | ១៦ ម៉ោង |
| – ក្រោយឧត្ដមសិក្សា | ១០ ម៉ោង | ១៤ ម៉ោង |
| **ថ្នាក់បណ្ដុះបណ្ដាលរយៈពេលខ្លី** | | |
| – ថ្នាក់កម្រិតពាក់កណ្ដាលមធ្យម | ១៦ ម៉ោង | ១ម៉ោងទ្រឹស្ដីស្មើនឹង ២ម៉ោងពិភាក្សា |
| – ថ្នាក់កម្រិតមធ្យម | ១៤ ម៉ោង | សំណួរ ឬអនុវត្តជាក់ស្ដែង |
| **ថ្នាក់វិក្រឹតការ** | | |
| – ថ្នាក់កម្រិតពាក់កណ្ដាលមធ្យម | ១៦ ម៉ោង | ១ម៉ោងទ្រឹស្ដីស្មើនឹង ២ម៉ោងពិភាក្សា |
| – ថ្នាក់កម្រិតមធ្យម | ១៤ ម៉ោង | សំណួរ ឬអនុវត្តជាក់ស្ដែង |

ខ) – សាស្ត្រាចារ្យ គ្រូបង្រៀន ដែលមានក្របខ័ណ្ឌខ្ពស់ ហើយទៅបង្រៀននៅគ្រឹះស្ថានសិក្សាទាប ត្រូវ អនុវត្តរបបម៉ោងកំណត់ទៅតាមក្របខ័ណ្ឌរបស់ខ្លួន ។

– សាស្ត្រាចារ្យ គ្រូបង្រៀន ដែលមានក្របខ័ណ្ឌទាប ហើយទៅបង្រៀននៅគ្រឹះស្ថានសិក្សាខ្ពស់ត្រូវអនុវត្តរបបម៉ោងកំណត់ទៅតាមកម្រិតគ្រឹះស្ថានសិក្សានោះ។

– ក្របខ័ណ្ឌបច្ចេកទេស ដែលមានភារកិច្ចជួយរៀបចំ និងធ្វើការនៅតាមទីពិសោធន៍ រោងជាងសិក្សា ត្រូវបំពេញភារកិច្ចប្រចាំសប្តាហ៍ តាមការកំណត់ដូចខាងក្រោមៈ

– កម្មករមន្ទីរពិសោធន៍ និង រោងជាងសិក្សា ៣៦ ម៉ោង

– បរិវច្ឆេការី គ្រូអនុវត្តនៅមន្ទីរពិសោធន៍ និងរោងជាងសិក្សា ៣០ ម៉ោង

**មាត្រា ៣.–**

– អ្នកដែលមានភារកិច្ចបង្រៀនជារបបម៉ោងបន្ថែម ត្រូវកំណត់យ៉ាងច្រើនបំផុត ៤៨ ម៉ោងក្នុងមួយខែ។

– មន្ត្រីរាជការទាំងអស់អាចបង្រៀនម៉ោងបន្ថែមជាអតិបរមា ចំនួន ៣២ ម៉ោង ក្នុងមួយខែ។

**មាត្រា ៤.–**

– **អំពីប្រាក់ម៉ោងបន្ថែមៈ**

ក) សាស្ត្រាចារ្យ គ្រូបង្រៀន ដែលបានបង្រៀនលើសពីចំនួនម៉ោងកំណត់ ដូចក្នុងមាត្រា ២ ត្រូវបានទទួលប្រាក់កម្រៃម៉ោងបន្ថែម ក្នុងមួយម៉ោងមានតម្លៃដូចតារាងខាងក្រោមៈ

| **កម្រិតសិក្សា** / **សញ្ញាប័ត្រ ឬក្របខ័ណ្ឌ** | – មធ្យមសិក្សាបច្ចេកទេស<br>– បណ្តុះបណ្តាលវិជ្ជាជីវៈ<br>– វិទ្យាល័យ<br>– អនុវិទ្យាល័យ | ឧត្តមសិក្សា | ក្រោយឧត្តមសិក្សា |
|---|---|---|---|
| **សាស្ត្រាចារ្យថ្នាក់ អនុបណ្ឌិត ឬ ខ I ៤ ឡើង ទៅ** | | ៩.៣០០ ៛<br>“ប្រាំបួនពាន់បីរយរៀល” | ១០.៤០០៛<br>“ដប់ពាន់បួនរយរៀល” |
| **សញ្ញាប័ត្រឧត្តមសិក្សា ក្របខ័ណ្ឌ ខ I** | ៥.២០០ ៛<br>“ប្រាំពាន់ពីររយរៀល” | ៧.៨០០ ៛<br>“ប្រាំពីរពាន់ប្រាំបីរយរៀល” | |
| **សញ្ញាប័ត្រមធ្យមសិក្សា ក្របខ័ណ្ឌ ខ II** | ២.៦០០ ៛<br>“ពីរពាន់ប្រាំមួយរយរៀល” | ២.៦០០ ៛<br>“ពីរពាន់ប្រាំមួយរយរៀល” | |
| **ប្រភេទខ III គ I ឬគ II** | ២.០០០ ៛<br>“ពីរពាន់រៀល” | ២.០០០ ៛<br>“ពីរពាន់រៀល” | |

**ខ) ករណីពិសេសៈ**

– ចំពោះមន្ត្រីរាជការដែលបានចាត់តាំងជាផ្លូវការ អោយទៅបង្រៀនជាគ្រូជំនួយនៅសាលាមធ្យមសិក្សាឯកទេស សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានសិក្សាផ្សេងៗរបស់រដ្ឋ ត្រូវអនុវត្តរបបម៉ោងបន្ថែម ដោយគិតជាទឹកប្រាក់ម៉ោងបន្ថែមទៅតាមសញ្ញាប័ត្រ ឬក្របខ័ណ្ឌរបស់សាមីជន។

- ចំពោះមន្ត្រីរាជការដែលមានតួនាទី ចាប់ពីអនុប្រធាននាយកដ្ឋានឡើងទៅ និងដែលបានចាត់តាំងជាផ្លូវការ អោយទៅបង្រៀន ឬធ្វើជាគ្រូជំនួយ ហើយមានបៀវត្សក្នុងតារាង "ក"រឺ "ខ" តែសាមីខ្លួនពុំមានសញ្ញាប័ត្រស្មើ ឬខ្ពស់ជាងសញ្ញាប័ត្រឧត្តមសិក្សាទេនោះ ត្រូវគិតប្រាក់ម៉ោងបន្ថែមដូចគ្រូបង្រៀនក្នុងប្រភេទ **ខ I**។
- ចំពោះអ្នកឯកទេសផ្សេងៗ មិនមែនជាមន្ត្រីរាជការ ដែលត្រូវអញ្ជើញមកអោយបង្រៀន ត្រូវស្នើសុំទៅក្រសួង តាមឋានានុក្រម ដើម្បីចេញលិខិតឧទ្ទេសនាម ដោយមានភ្ជាប់ចម្លងសញ្ញាប័ត្រ ឬសំណុំលិខិតផ្សេងៗ។ ការគិតប្រាក់ម៉ោងបន្ថែម ត្រូវគិតតាមសញ្ញាប័ត្រ និងកម្រិតភូមិសិក្សា ដែលសាមីជនបានបង្រៀន។

**មាត្រា ៥.–**

អនុក្រឹត្យនេះអនុវត្តចំពោះតែមធ្យមសិក្សាចំណេះទូទៅ បណ្តុះបណ្តាលវិជ្ជាជីវៈមធ្យមសិក្សាឯកទេស និងឧត្តមសិក្សា។ ចំពោះបឋមសិក្សានឹងមានកំណត់ក្នុងអនុក្រឹត្យដោយឡែក។

**មាត្រា ៦:–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៧:–**

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុងទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន។

**មាត្រា ៨: –**

អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៦ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

**នាយករដ្ឋមន្ត្រីទី ១** **នាយករដ្ឋមន្ត្រីទី ២**

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យព្រះមហាក្សត្រ
- ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- គ្រប់ក្រសួង ស្ថាប័ន
- ដូចមាត្រា ៧
- កាលប្បវត្តិ –ឯកសារ